រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# *សេចក្តីប្រកាសព័ត៌មាន*

## កម្មវិធីតម្លាភាពបន្តជំរុញការកែលម្អលក្ខខណ្ឌការងារ

## ថ្ងៃទី៣ខែកក្កដាឆ្នាំ២០១៤

ភ្នំពេញ៖ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការអន្តរជាតិខាងការងារ បានចេញផ្សាយ របាយការណ៍តម្លាភាពលើប្រព័ន្ធអ៊ីនធើណិតនៅថ្ងៃនេះ ដោយបង្ហាញថាតើរោងចក្រកាត់ដេរនីមួយៗបានធ្វើល្អដល់កម្រិតណាលើលក្ខខណ្ឌការងារសំខាន់ៗ។

រោងចក្របីក្នុងចំណោមរោងចក្រទាំង១២ ដែលនៅក្នុងក្រុមការអនុវត្តច្បាប់នៅមានកម្រិតទាប បានធ្វើការកែលម្អចំនុចចំនួន ៣៣ ដែលអាចផ្ទៀងផ្ទាត់បាន ហើយជាលទ្ធផលរោងចក្រទាំងបីនោះត្រូវបានដកចេញពីតារាងនៃការអនុវត្តច្បាប់មានកម្រិតទាប។ រោងចក្រដែលនៅក្នុងក្រុមការអនុវត្តច្បាប់នៅមានកម្រិតទាប ជារោងចក្រដែលធ្លាក់ក្រោមពីរគម្លាតគំរូ ពីកម្រិតមធ្យមក្នុងការអនុលោមលើចំនុនចំនួន៥២ ក្នុងចំណោមរោងចក្រដែលត្រូវបានត្រួតពិនិត្យបីដង ឬលើសពីបីដង ដោយគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

រោងចក្រចំនួន មួយភាគបីនៃរោងចក្រចំនួន៩២ដែលត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ស្តីពីបញ្ហាចំបងៗ បានធ្វើការកែលម្អលើចំនុចទាំង២១ តាមរយៈការប្រមើលទុកជាមុនថា ពួកគេនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរបាយការណ៍តម្លាភាពនេះ។ ចំនួនសរុបនៃការរំលោភបំពានលើបញ្ហាចំបងៗ នៅក្នុងក្រុមរោងចក្រនេះ បានធ្លាក់ចុះពី ១៣៤ ទៅ៨៧ ចំនុច រវាងខែមេសា និង ខែមិថុនាឆ្នាំ២០១៤ ដែលស្មើនឹង ៣៥ភាគរយនៃការកែលម្អ។

រោងចក្រចំនួន២៤ នៅក្នុងទិន្នន័យនេះ ដែលស្មើនឹង ២៦ ភាគរយ បានគោរពត្រឹមត្រូវរួចជាស្រេចតាមតម្រូវការច្បាប់មូលដ្ឋាន ចំនួន ២១ចំនុចក្នុងប្រភេទបញ្ហាចំបងៗនេះ។ រោងចក្រចំនួន១៩ទៀត ក៏បានធ្វើការកែលម្អ ដើម្បីចូលទៅក្នុងក្រុមរោងចក្រដែលគោរពបានទាំង២១ចំនុចនេះ ដែលមានចំនួនសរុប ៤៣រោងចក្រ ស្មើនឹង ៤៧ភាគរយ ដោយមិនមានការរំលោភបំពានលើចំនុចណាមួយក្នុងក្រុមបញ្ហាចំបងៗ។

ការប្រៀបធៀបនៃការអនុវត្តរបស់រោងចក្រចំនួន៩៣ថ្មី ដែលត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍តម្លាភាពនេះ ជាមួយនឹង ការអនុវត្តរបស់រោងចក្រក្នុងរបាយការណ៍សំយោគស្តីពីលក្ខខណ្ឌការងារ ដែលត្រូវបានត្រួតពិនិត្យពីខែឧសភាឆ្នាំ២០១៣ដល់ខែមេសាឆ្នាំ២០១៤ បានជួយបង្ហាញពីឥទ្ធិពលនៃរបាយការណ៍តម្លាភាពលើលក្ខខណ្ឌការងារ។

- រោងចក្រធ្វើការហ្វឹកហាត់ជម្លៀសកម្មករចេញពីអាគារពេលមានអាសន្នកើនឡើងពី៥៧%ទៅ៧៩%

- រោងចក្ររើងអើងកម្មករ មានការថយចុះ ពី២០% ទៅ ៧%

លោកស្រី ជាល តាក់កឺ ដែលជាប្រធានប្រឹក្សាបច្ចេកទេសនៃគំរោងរោងចក្រកាន់

Better Factories Cambodia

International Labour Organization
#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642
Tel (+855) 23 212 847
(+855) 23 220 362
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org

តែប្រសើរនៅកម្ពុជា បានថ្លែងថា ៖ "តាមរយៈតម្លាភាព ពួកយើងបានមើលឃើញពីការផ្លាស់ប្តូរនៅក្នុងរោងចក្រ ដែលមិនមានការផ្លាស់ប្តូរជាច្រើនឆ្នាំ។

អត្ថប្រយោជន៍មួយចំនួនដែលត្រូវបានផ្តល់រួមមាន ការបង់ប្រាក់អត្ថប្រយោជន៍ទាក់ទិននឹងអតីតភាពការងារ ដែលផ្តល់ប្រាក់ដល់ហោប៉ៅរបស់កម្មករ ហើយអត្ថប្រយោជន៍ទាំងអស់នេះមិនអាចបញ្ឈប់នៅពេលដែលពួកគេត្រូវបានផ្តល់។"

លោកស្រី បន្តទៀតថា៖ "បន្ថែមពីលើនេះ ពួកយើងបានឃើញជំហ៊ានមួយ ដែលប្រកបដោយការលើកទឹកចិត្ត នៅពេលដែលមន្ត្រីពីក្រសួងពាណិជ្ជកម្ម និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះរោងចក្រ ដែលនៅក្នុងក្រុមការអនុវត្តច្បាប់នៅមានកម្រិតទាប។ ការខិតខំប្រឹងប្រែងបែបនេះមានសក្តានុពលក្នុងការផ្លាស់ប្តូរដ៏ធំមួយ ជាពិសេស រោងចក្រអនុវត្តច្បាប់នៅមានកម្រិតទាប ដែលធ្វើឱ្យខូចមុខមាត់ឧស្សាហកម្មទាំងមូល។"

ការអនុវត្តច្បាប់របស់សហជីព ជាមួយនឹងតម្រូវការច្បាប់ ក្នុងការធ្វើកូដកម្មក៏ត្រូវបានបង្ហាញផងដែរ។ រាល់កូដកម្មដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍តម្លាភាពនៅខែកក្កដាឆ្នាំ២០១៤  គ្មានកូដកម្មណាមួយដែលបានធ្វើឡើងនៅក្នុងរោងចក្រ បានគោរពតម្រូវការច្បាប់ទាំងនេះទេ។

សម្រាប់ពត៌មានបន្ថែមពីរោងចក្រទាំងអស់ និងសហជីព ដែលត្រូវបានគ្របដណ្តប់នៅក្នុងរបាយការណ៍តម្លាភាពនេះអាចរកបាននៅលើគេហទំព័រ www.betterfactories.org/transparency។

របាយការណ៍សង្ខេបទិន្នន័យនៃកម្មវិធីតម្លាភាពត្រូវបានភ្ជាប់ជាមួយ

សម្រាប់ពត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់

លោក គាំ ទីវា

មន្ត្រីទំនាក់ទំនង

ទូរស័ព្ទ +៨៥៥៨៩៤២៦៦៩៦

អ៊ីម៉េល៖ tivea@ilo.org